- លោក ជូ គីមឡេង ប្រធាននាយកដ្ឋានហិរញ្ញវត្ថុក្រៅប្រទេស សមាជិក
- លោក ប្រាក់ ឡេង ប្រធានអង្គភាពមន្ទីរ សមាជិក
- លោក ទន្សុ វ៉ិជាទុន្នរ នាយកសាលាមធ្យមសិក្សាហិរញ្ញវត្ថុ សមាជិក
- លោក ហ៊ាង ឈាងវ័ណ្ណ ប្រធាននាយកដ្ឋានទុនវិនិយោគក្នុងមូលដ្ឋាន សមាជិក
- លោក ស៊ុន គីមស្រ៊ុន អនុប្រធាននាយកដ្ឋានទុនវិនិយោគក្នុងមូលដ្ឋាន សមាជិក
- លោក អ៊ីុន ឆាំងអ៊ឹម ប្រធានក្រុមហ៊ុនជាតិធានារ៉ាប់រងកម្ពុជា សមាជិក
- លោក ខូច ហៃ ប្រធានការិយាល័យបុគ្គលិក សមាជិក
- លោក ស៊ីន ចន្ទ្រី ប្រធានការិយាល័យក្របខ័ណ្ឌបៀវត្ស សមាជិក

**ប្រការ ២** : គណៈកម្មការបច្ចេកទេសសំរបសំរួល និង កែទំរង់រដ្ឋបាលប្រចាំក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ មានភារកិច្ចចូលរួមសហការ និង បង្កលក្ខណៈងាយស្រួលដល់គណៈប្រតិភូរបស់ គណៈកម្មាធិការបច្ចេកទេសអន្តរក្រសួង ដើម្បីកែទំរង់រដ្ឋបាលដោយមានការចូលរួមពីអ្នកជំនាញការ UNDP សំរេចភារកិច្ចជោគជ័យលើការងារកែទំរង់រដ្ឋបាលនៅក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

**ប្រការ ៣** : នាយកខុទ្ទកាល័យ ប្រធាននាយកដ្ឋានបុគ្គលិក ប្រធានមន្ទីរ និង សាមីខ្លួនដូចក្នុងប្រការ ១ ខាងលើ ត្រូវទទួលបន្ទុកអនុវត្តតាមប្រកាសនេះ ។

ហត្ថលេខា និង ត្រា

**គាត ឈន់**

* * *

រាជធានីភ្នំពេញ , ថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ១៩៩៦

## ប្រកាសលេខ ១៧១ សហវ.ប្រក

## ការបង្កើតការិយាល័យពត៌មានវិទ្យា

ទេសរដ្ឋមន្ត្រីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

- បានឃើញ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្ដីពីការតែងតាំងរាជ

រដ្ឋាភិបាលកម្ពុជា ។

- បានឃើញច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រីដែលប្រកាសអោយប្រើ ដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ។
- បានឃើញអនុក្រឹត្យ នស.រកត.១០៩៤.៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើ ដោយព្រះរាជក្រមលេខ នស.រកម ០១៩៦.១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ។
- បានឃើញច្បាប់ ស្តីពីហិរញ្ញវត្ថុសំរាប់ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ០២..នស ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ និង ច្បាប់ស្តីពីការកែតម្រូវនៃច្បាប់ហិរញ្ញវត្ថុសំរាប់ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ០៨.នស,៩៤ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៤
- បានឃើញច្បាប់ ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ដែលប្រកាសអោយប្រើដោយព្រះព្រះរាជក្រមលេខ ១១.នស.៩៤ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤ និង ច្បាប់ស្តីពីការកែតម្រូវនៃច្បាប់ហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ជស.រកម.០៩៩៥.០១ ចុះថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ១៩៩៥
- បានឃើញការងារចាំបាច់របស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- តាមសំណើរបស់ប្រធាននាយកដ្ឋានពន្ធដារ ។

## សំរេច

**ប្រការ ១** : ត្រូវបានបង្កើតក្នុងនាយកដ្ឋានពន្ធដារនូវការិយាល័យពត៌មានវិទ្យា

**ប្រការ ២** : ការិយាល័យនេះមានភារកិច្ច :

- កំណត់នយោបាយទូទៅរបស់នាយកដ្ឋានពន្ធដារអំពីពត៌មានវិទ្យា និង ចូលរួមធ្វើអោយនយោបាយនេះដំណើរការបានល្អ
- សិក្សាស្រាវជ្រាវពត៌មាននៃផ្នែកទាំងឡាយ
- កំណត់សេចក្តីត្រូវការ នៃការអនុវត្តន៍ពត៌មានវិទ្យា និង ចូលរួមធ្វើអោយដំណើរការនូវគំរោងពត៌មានសារពើពន្ធ

**ប្រការ ៣** : នាយកខុទ្ទកាល័យ ប្រធានមន្ទីរ ប្រធាននាយកដ្ឋានបុគ្គលិក ប្រធាននាយកដ្ឋានពន្ធដារ និង អង្គភាពដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តតាមប្រកាសនេះ ។

ហត្ថលេខា និង ត្រា

**គាត ឈន់**

* * *

រាជធានីភ្នំពេញ , ថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ១៩៩៦

**ប្រកាសលេខ ១៧២ ប្រក.សហវ.ពដ**

**ការបង្កើតការិយាល័យមេធាវីនាន**

ទេសរដ្ឋមន្ត្រីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

- បានឃើញ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា ។
- បានឃើញច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រីដែលប្រកាសអោយប្រើ ដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ។
- បានឃើញព្រះរាជក្រឹត្យ ន.ស.រកត ១០៩៤.៩៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើ ដោយព្រះរាជក្រមលេខ នស.រកម ០១៩៦.១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ។
- បានឃើញច្បាប់ ស្តីពីហិរញ្ញវត្ថុសំរាប់ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ០២ ន.ស ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ និងច្បាប់ស្តីពីការកែតម្រូវនៃច្បាប់ហិរញ្ញវត្ថុសំរាប់ឆ្នាំ ៩៤ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ០៨ ន.ស ៩៤ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៤
- បានឃើញច្បាប់ ស្តីពីហិរញ្ញវត្ថុសំរាប់គ្រប់គ្រងឆ្នាំ ១៩៩៥ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ១១.នស.៩៤ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤ និង ច្បាប់ស្តីការកែតម្រូវនៃច្បាប់ហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ដែលប្រកាសអោយ